**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ : ៥០០ សជណ

ថ្ងៃ សុក្រ ១៥ រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០១៨

**ជម្រាបមក**
**លោក ទាវ វណ្ណុល**
**ប្រធានគណបក្សភ្លើងទៀន**

**កម្មវត្ថុ** ៖ ស្ដីពីការជូនដំណឹងអំពីលទ្ធផល នៃសមាជវិសាមញ្ញរបស់**គណបក្សភ្លើងទៀន**។
**យោង** ៖ - ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីគណបក្សនយោបាយ
- ព្រះរាជក្រមលេខ នស/រកម/០៣១៧/០០៣ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីគណបក្សនយោបាយ
- ព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៧ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីគណបក្សនយោបាយ និងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីគណបក្សនយោបាយ
- ប្រកាសលេខ១៩៣ ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ របស់ក្រសួងមហាផ្ទៃ ស្ដីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយ
- លិខិតលេខ២០២៤ សជណ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ០០៥/១៨ គ.ក.ទ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ របស់គណបក្សភ្លើងទៀន។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោកប្រធានគណបក្ស ជ្រាបថា ក្រសួងមហាផ្ទៃ បានទទួលរួចហើយនូវលិខិតរបស់គណបក្សភ្លើងទៀនដូចមានចុះក្នុងយោងខាងលើ។ ក្រសួងមហាផ្ទៃ ទទួលស្គាល់លទ្ធផល នៃសមាជវិសាមញ្ញរបស់គណបក្សភ្លើងទៀន ដែលបានប្រារព្ធធ្វើកាលពីថ្ងៃចន្ទ ១២កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ដោយបានអនុម័តធ្វើវិសោធនកម្មលក្ខន្តិកៈ និងបានបោះឆ្នោតគាំទ្រលោក ទាវ វណ្ណុល ជាប្រធានគណបក្ស លោក ចេប គីមអ៊ាង ជាអនុប្រធានគណបក្ស ព្រមទាំងបោះឆ្នោតគាំទ្រសមាជិកគណៈកម្មាធិការនាយកគណបក្សចំនួន ២៥( ម្ភៃប្រាំ )រូប និងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្សចំនួន ០៩( ប្រាំបួន )រូប។

ទន្ទឹមនេះ ក្រសួងស្នើឲ្យគណបក្សភ្លើងទៀន បំពេញនូវលក្ខខណ្ឌនានា ដែលបានកំណត់ក្នុងមាត្រា២៦ថ្មី នៃច្បាប់ស្ដីពីគណបក្សនយោបាយ។

អាស្រ័យហេតុនេះ សូមលោកប្រធានគណបក្សភ្លើងទៀន ជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

សូមលោកប្រធានគណបក្ស ទទួលនូវសេចក្ដីរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

**ចម្លងជូន៖**
- តុលាការកំពូល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងព្រះបរមរាជវាំង
- ក្រសួងយុត្តិធម៌
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- សាលារាជធានីភ្នំពេញ និងគ្រប់សាលាខេត្ត
(ដើម្បីជូនជ្រាប)
- ឯកសារ - កាលប្បវត្តិ